**ព្រះរាជក្រឹត្យ**

នស/រកត/១២១៤/១៤៧១

**ស្តីពី**

**ការកែសម្រួលមាត្រា១០ថ្មី មាត្រា១៤ថ្មី មាត្រា១៥ថ្មី និងមាត្រា១៦ថ្មីនៃព្រះរាជក្រឹត្យ លេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ មាត្រា១៣ថ្មី មាត្រា៣០ថ្មី និងមាត្រា១១ថ្មីស្ទួន នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ និងមាត្រា៦១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១៣និងមាត្រា៣០ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និងការកែសម្រួលមាត្រា១១ថ្មី នៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦១ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ .-**

មាត្រា១០ថ្មី មាត្រា១៤ថ្មី មាត្រា១៥ ថ្មីនិងមាត្រា១៦ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា មាត្រា១៣ថ្មី មាត្រា៣០ថ្មី និងមាត្រា១១ថ្មីស្ទួន នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១៣និងមាត្រា៣០នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សានិងការកែសម្រួលមាត្រា១១ថ្មីនៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និងមាត្រា៦១នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ត្រូវបានកែសម្រួលដូចខាងក្រោម៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា១០ ._ថ្មី(ពីរ)**

**គ.ឧ.ក**. មានសមាជិកអចិន្ត្រៃយ៍និងសមាជិកជ្រើសតាំង។

ក. សមាជិកអចិន្ត្រៃយ៍

សមាជិកអចិន្ត្រៃយ៍រួមមានៈ

- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធាន
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប អនុប្រធាន
- អគ្គលេខាធិការ**គ.ឧ.ក**. សមាជិក។

ខ. សមាជិកជ្រើសតាំង

សមាជិកជ្រើសតាំងមានចំនួនយ៉ាងតិច១១(ដប់មួយ)រូប ដែលត្រូវជ្រើសរើសចេញពីឥស្សរជនឬបញ្ញវន្តកម្ពុជាដែលមានសញ្ញាបត្រឧត្តមសិក្សាចាប់ពីកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ និងមានជំនាញផ្នែកគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ឬមានជំនាញក្នុងការកសាងគោលនយោបាយផ្នែកឧត្តមសិក្សា។

សមាជិកជ្រើសតាំងត្រូវជ្រើសរើសតាមនីតិវិធីដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ។

**គ.ឧ.ក**. មានអ្នកជំនាញពីររូបដែលមានបទពិសោធនៅក្នុងស្ថាប័នទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សានៃប្រទេសនានាជាទីប្រឹក្សា។

**មាត្រា១១ ._ថ្មី(បី)**

សមាជិក **គ.ឧ.ក**. ទាំងអស់ត្រូវជ្រើសតាំងឱ្យបម្រើការងារមិនពេញម៉ោង និងទទួលប្រាក់ឧបត្ថម្ភតាមរយៈក្រសួងអប់រំ យុវជន និងកីឡា។ ប្រាក់ឧបត្ថម្ភរបស់សមាជិក **គ.ឧ.ក**. ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ប្រធាន **គ.ឧ.ក**.។

**គ.ឧ.ក**. មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការដែលដឹកនាំដោយអគ្គលេខាធិការមួយរូបនិងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។ អគ្គលេខាធិការនិងអគ្គលេខាធិការរងត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ**គ.ឧ.ក**. ត្រូវកំណត់ដោយអនុក្រឹត្យ។

**គ.ឧ.ក**.មានបទបញ្ជាផ្ទៃក្នុង រូបសញ្ញា និងត្រាមួយដោយឡែករបស់ខ្លួន។

**មាត្រា១៣ ._ថ្មី(ពីរ)**

សមាជិក **គ.ឧ.ក**. មានអាណត្តិបីឆ្នាំ ហើយអាចត្រូវជ្រើសរើសបន្តរយៈពេលបីឆ្នាំទៀតបានតាមរយៈការតែងតាំង ឬតាមរយៈការបោះឆ្នោត ដោយអនុវត្តតាមនីតិវិធីកំណត់នៅក្នុងព្រះរាជក្រឹត្យនេះ។

**មាត្រា១៤ .-ថ្មី(ពីរ)**

ដើម្បីជ្រើសតាំងសមាជិក **គ.ឧ.ក.** ប្រធាន **គ.ឧ.ក.** ត្រូវបង្កើតគណៈកម្មការជ្រើសតាំងមួយសម្រាប់ជ្រើសតាំងបេក្ខភាពសមាជិក **គ.ឧ.ក.**។ ដើម្បីឱ្យដំណើរការជ្រើសតាំងនេះប្រព្រឹត្តទៅដោយប្រសិទ្ធភាពខ្ពស់ ប្រធាន **គ.ឧ.ក.** ត្រូវជូនដំណឹងទៅគណៈកម្មការជ្រើសតាំងឱ្យធ្វើការជ្រើសតាំងបេក្ខជនសម្រាប់តំណែងសមាជិក**គ.ឧ.ក.**។

**មាត្រា១៥ .-ថ្មី(ពីរ)**

ក្នុងការជ្រើសតាំងបេក្ខភាពតំណែងសមាជិក **គ.ឧ.ក.** គណៈកម្មការជ្រើសតាំងត្រូវធ្វើការជ្រើសតាំងតាមរយៈការបោះឆ្នោត ដោយយកសំឡេងភាគច្រើនដាច់ខាតនៃសមាជិកចូលរួម។ បន្ទាប់មកគណៈកម្មការនេះ ត្រូវបញ្ជូនបញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោតទៅប្រធាន **គ.ឧ.ក.**។ ផ្អែកលើបញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោតនោះ ប្រធាន**គ.ឧ.ក.** ត្រូវរៀបចំស្នើសុំតែងតាំងសមាជិក**គ.ឧ.ក.** ដោយព្រះរាជក្រឹត្យ។ ក្នុងករណីតំណែងសមាជិក **គ.ឧ.ក.**ណាមួយនៅទំនេរ គណៈកម្មការជ្រើសតាំងមានភារកិច្ចធ្វើការជ្រើសតាំងសមាសភាពថ្មីមកជំនួស។

គណៈកម្មការជ្រើសតាំងអាចមានសិទ្ធិស្នើសុំតំណាងពីក្រសួងអាណាព្យាបាល ឬស្ថាប័នពាក់ព័ន្ធដើម្បីចូលរួមជាសមាជិក **គ.ឧ.ក.**។

**មាត្រា១៦ .-ថ្មី(ពីរ)**

សមាសភាពនៃគណៈកម្មការជ្រើសតាំងមានដូចតទៅៈ

| | | |
|---|---|---|
| -រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | | ប្រធាន |
| -រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១រូប | អនុប្រធាន |
| -តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| -អគ្គលេខាធិការ **គ.ឧ.ក.** | | សមាជិក |
| -តំណាងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ | ១រូប | សមាជិក |
| -តំណាងគ្រឹះស្ថានឧត្តមសិក្សាឯកជន | ១រូប | សមាជិក |
| -តំណាងក្រសួងអាណាព្យាបាលនៃគ្រឹះស្ថានឧត្តមសិក្សានីមួយៗ | | សមាជិក |

ក្នុងករណីចាំបាច់   គណៈកម្មការជ្រើសតាំងមានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍមួយចំនួនតាមការចាំបាច់ ឱ្យចូលរួមជាអ្នកសង្កេតការណ៍។

**មាត្រា៣០ .- ថ្មី(ពីរ)**

ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានត្រូវមានមុខវិជ្ជាដែលស្រង់ចេញពីវិស័យសិក្សាទាំងបួនផ្នែក ដូចខាងក្រោម៖

- សិល្បៈនិងមនុស្សសាស្ត្រ
- គណិតសាស្ត្រ វិទ្យាសាស្ត្រ និងកុំព្យូទ័រវិទ្យា
- វិទ្យាសាស្ត្រសង្គម
- ភាសាបរទេស។

ចំនួនក្រេឌីតនៃមុខវិជ្ជាក្នុងវិស័យនីមួយៗត្រូវមានយ៉ាងតិច១០(ដប់)ភាគរយនៃពិន្ទុក្រេឌីតសរុបសម្រាប់វិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។ មុខវិជ្ជាដែលនិស្សិតជ្រើសរើសនៅក្នុងឆ្នាំសិក្សាមូលដ្ឋាន ត្រូវស្របទៅនឹងផ្នែកជំនាញដែលនិស្សិតជ្រើសរើស   ប៉ុន្តែនិស្សិតត្រូវតែសិក្សាមុខវិជ្ជាចាំបាច់សម្រាប់ការចូលសិក្សានៅកម្រិតបរិញ្ញាបត្រ។

**គ.ទ.ក**. មានសិទ្ធិកែសម្រួលកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។

**មាត្រា៦១ .- ថ្មី**

ការចំណាយសម្រាប់ដំណើរការរបស់**គ.ទ.ក**.  ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា។

**គ.ទ.ក**.មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រាពីរ .-**

ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សានិងព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១៣និងមាត្រា៣០នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សានិងការកែសម្រួលមាត្រា១១ថ្មីនៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលមាត្រា១០  មាត្រា១១  មាត្រា១៤  មាត្រា១៥/...

និងមាត្រា១៦នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាមី ._**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៤

នស.រកត.១២១៤.១៤៣៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហត្ថលេខា**

**ហង់ ជួន ណារ៉ុន**

លេខៈ ១៤៩៩ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**